ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដំណាំដំឡូងមី





ខែកញ្ញា ឆ្នាំ២០២១

# ដំណាំដំឡូងមី

## ១-ផ្ទៃដីដាំដុះ និងបរិមាណផល ឆ្នាំ២០១៩-២០២០

| ឆ្នាំ | ផ្ទៃដីដាំដុះ (ហ.ត) | ទិន្នផល (តោន/ហ.ត) | បរិមាណផលសរុប (តោន) |
|---|---|---|---|
| ២០១៩ | ៦៥២ ៥៣១ | ២០.៧០ | ១៣ ៥១២ ៧៥៦ |
| ២០២០ | ៦១៧ ០៩០ | ២០.៥៥ | ១២ ៦៨៣ ៩៨៧ |

## ២-ការនាំចេញដំឡូងមីកម្ពុជា ឆ្នាំ ២០១៩ - ឆ្នាំ ២០២០ និងរយៈពេល៨ខែ ឆ្នាំ២០២១

| បរិយាយ | បរិមាណ (តោន) | | | ទិសដៅនាំចេញ |
|---|---|---|---|---|
| | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ៨ខែ ឆ្នាំ២០២១ | |
| ចំណិតដំឡូងមីក្រៀម | ១ ៦២៦ ១៦៥ | ១ ៥១៦ ៤៧៦ | ១ ២៨៣ ៩០៣ | ថៃ វៀតណាម ចិន |
| ដំឡូងមីស្រស់ | ១ ៦០៨ ៤៥០ | ៧២៣ ៥៩០ | ៤៦៩ ៣០០ | ថៃ វៀតណាម |
| ម្សៅដំឡូងមី | ៥៦ ៨៧៤ | ៣៤ ៩៣៥ | ១៨ ៧០១ | ថៃ វៀតណាម ចិន អ៊ីតាលី ហូឡង់ កាណាដា ឥណ្ឌា ប៉ាគីស្ថាន |

ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រៅពីការនាំចេញផ្លូវការខាងលើ ផលិតផលដំឡូងមីកម្ពុជាត្រូវបាននាំចេញក្រៅផ្លូវការតាមច្រករបៀងទៅប្រទេសជិតខាង។

ក្នុងបរិមាណដំឡូងមីស្រស់ចំនួន ១ ០០០ គ.ក ទទួលបានបរិមាណដំឡូងមីចំណិតក្រៀមចំនួន ៤២% ស្មើនឹង ៤២០ គ.ក ក្នុងសំណើម១៤% កាប់ដោយម៉ាស៊ីន ប៉ុន្តែបើកាប់ដោយដៃអាចទទួលបានដំឡូងមីចំណិតក្រៀមពី៤៧%ទៅ៥០% ចំពោះពូជដំឡូងទឹក រីឯពូជដំឡូងមីម្សៅដែលមាកម្រិតជាតិម្សៅខ្ពស់ដូចជាពូជ ហ៊ុយ ប៊ុង គឺអាចទទួលបានបរិមាណដំឡូងមីស្ងួតពី៦០% ទៅ៧០%។ ក្នុងបរិមាណដំឡូងមីស្រស់ ១ ០០០ គ.ក ទទួលបានបរិមាណម្សៅដំឡូងមី ២០០ គ.ក ។ កម្រិតជាតិម្សៅចន្លោះពី ២០ ទៅ ២៤% ទៅតាមប្រភេទពូជ។

## ៣-ផ្ទៃដីដាំដុះ និងបរិមាណផលដំឡូងមីតាមបណ្តាខេត្ត ឆ្នាំ២០២០

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីប្រមូលផល (ហ.ត) | បរិមាណផល (តោន) |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | 77,880 | 1,743,489 |
| ២ | បាត់ដំបង | 107,060 | 2,549,092 |
| ៣ | កំពង់ចាម | 20,492 | 406,965 |
| ៤ | កំពង់ឆ្នាំង | 275 | 1,714 |

| | | | |
|---|---|---|---|
| ៥ | កំពង់ស្ពឺ | 53 | 1,007 |
| ៦ | កំពង់ធំ | 47,497 | 1,040,487 |
| ៧ | កំពត | 496 | 10,486 |
| ៨ | កណ្ដាល | 0 | 0 |
| ៩ | កោះកុង | 40 | 307 |
| ១០ | ក្រចេះ | 74,946 | 1,474,608 |
| ១១ | មណ្ឌលគិរី | 13,965 | 220,745 |
| ១២ | ភ្នំពេញ | 4 | 44 |
| ១៣ | ព្រះវិហារ | 23,440 | 468,800 |
| ១៤ | ព្រៃវែង | 1,035 | 18,630 |
| ១៥ | ពោធិសាត់ | 23,736 | 474,720 |
| ១៦ | រតនគិរី | 14,553 | 208,443 |
| ១៧ | សៀមរាប | 37,655 | 607,143 |
| ១៨ | ព្រះសីហនុ | 0 | 0 |
| ១៩ | ស្ទឹងត្រែង | 10,985 | 230,685 |
| ២០ | ស្វាយរៀង | 5,710 | 102,056 |
| ២១ | តាកែវ | 2,072 | 31,080 |
| ២២ | ឧត្តរមានជ័យ | 61,438 | 1,302,566 |
| ២៣ | កែប | 4 | 50 |
| ២៤ | ប៉ៃលិន | 38,279 | 787,016 |
| ២៥ | ត្បូងឃ្មុំ | 55,475 | 1,003,855 |
| **សរុប** | | **617,090** | **12,683,987** |

**៤-ទីផ្សារ÷**

-ទីផ្សារដំឡូងមីរបស់កម្ពុជាគឺពឹងផ្អែកលើទីផ្សារប្រទេសថៃ និងវៀតណាម ដែលត្រូវបានគេចាត់ទុកត្រឹមតែជាប្រភពនៃការផ្គត់ផ្គង់បន្ថែមនៅពេលដែលផលិតផលក្នុងស្រុកនៃប្រទេសទាំងពីរនេះមិនអាចឆ្លើយតបនឹងសេចក្ដីត្រូវការក្នុងស្រុក និងមិនអាចបង្គ្រប់បរិមាណសម្រាប់ការនាំចេញបាន។ កត្តានេះធ្វើឱ្យផលិតផលដំឡូងមីកម្ពុជាងាយរងគ្រោះពីការឡើង-ចុះថ្លៃ ប្រែប្រួលទៅតាមតម្រូវការរបស់គេ។

-កសិករនៅតំបន់ភាគខាងលិច គឺលក់ដំឡូងមីចំណិតក្រៀមឱ្យឈ្មួញឬម្ចាស់សែឡូក្នុងស្រុក ដែលលក់បន្តឱ្យឈ្មួញថៃ និងឈ្មួញនាំចេញទៅវៀតណាម។ ឈ្មួញឬម្ចាស់សែឡូមិនទទួលទិញមើមដំឡូងមី

ស្រស់ទេ ព្រោះថៃមិនអនុញ្ញាតឱ្យនាំចូលដំឡូងមីស្រស់ឡើយ ។ ការនាំចេញមើមដំឡូងមីស្រស់បានខ្លះទៅប្រទេសថៃគឺធ្វើឡើងដោយលួចលាក់ មិនផ្លូវការតាមច្រករបៀង។ មានការប្រមូលទិញដំឡូងមីស្រស់ពីកសិករក្នុងបរិមាណតិចតួចពីសំណាក់ឈ្មួញវៀតណាម។

-កសិករនៅតំបន់ខេត្តកំពង់ចាម ត្បូងឃ្មុំ ភាគច្រើនគឺលក់មើមដំឡូងមីស្រស់ឱ្យឈ្មួញនាំចេញទៅវៀតណាម និងមួយចំនួនលក់ឱ្យរោងចក្រកែច្នៃម្សៅដំឡូងមីនៅស្ទួងដែលទទួលទិញក្នុងតម្លៃថោកជាងឈ្មួញនាំចេញពី៣០៛ ទៅ៥០៛/គ.ក។

-ការលក់ជាដំឡូងមីចំណិតក្រៀមទទួលបានប្រាក់ចំណេញជាងការលក់មើមដំឡូងមីស្រស់ គ្រាន់តែការធ្វើជាដំឡូងមីចំណិតក្រៀមចំណាយពេលពី ៥ទៅ៧ថ្ងៃ សម្រាប់ការហាលដំឡូង។

-បើផលដំឡូងរបស់កសិករមានគុណភាព គឺមិនខ្វះទេឈ្មួញរង់ចាំទទួលទិញ ក៏ប៉ុន្តែតម្លៃប្រែប្រួលទៅតាមតម្រូវការរបស់ប្រទេសជិតខាង។

**៥-និន្នាការតម្លៃ ÷**

| ផលិតផល | តម្លៃទាបបំផុត | តម្លៃខ្ពស់បំផុត |
|---|---|---|
| ដំឡូងមីស្រស់ | ១.៨បាត-២បាត/គ.ក | ២.៨បាត/គ.ក |
| ដំឡូងមីក្រៀម | ៤.៨បាត/គ.ក | ៦.៥បាត/គ.ក |

-បើលក់បានក្នុងតម្លៃទាបបំផុត ក៏កសិករអាចទទួលបានប្រាក់ចំណេញបន្តិចបន្តួចដែរ មិនខាតបង់ឡើយ លើកលែងតែជួបគ្រោះធម្មជាតិដែលធ្វើឱ្យទិន្នផលធ្លាក់ចុះខ្លាំង។

-ក្នុងរយៈពេល២ឆ្នាំ នេះ ឆ្នាំ២០២០ និងដើមឆ្នាំ២០២១ ផលិតផលដំឡូងមីមានតម្លៃល្អ ដែលអាចឱ្យកសិករទទួលបានផលចំណេញសមរម្យ។ តម្លៃក្នុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១ គឺដូចគ្នា÷

**ក-តម្លៃនៅតំបន់ខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន÷** (១បាត=១៣៣៛ អត្រាមធ្យមក្នុងខែកុម្ភៈ-មីនា ឆ្នាំ២០២១)

| ផលិតផល | សែទ្បូ<br>ទិញពីកសិករ | ឈ្មួញថៃទិញពីសែទ្បូ | ឈ្មួញវៀតណាម<br>ទិញស្រស់ពីកសិករ និងក្រៀមពីសែទ្បូ |
|---|---|---|---|
| ដំឡូងមីស្រស់ | | | ២.៨បាត-៣បាត/គ.ក<br>~៣៧២រៀល-៣៩៩៛/គ.ក |
| ដំឡូងមីក្រៀម | ៥.៨បាត-៦.២បាត/គ.ក<br>~៧៧១រៀល-៨២៤៛/គ.ក | ៦.៧បាត/គ.ក-៦.៨បាត/គ.ក<br>~៨៩១៛/គ.ក-៩០៤៛/គ.ក | ៦.៨បាត/គ.ក~៨៤៣៛/គ.ក<br>(ដំឡូងស្អាត មិនជាប់ដី និងស្ងួតល្អ) |

## ខ-តម្លៃនៅតំបន់ត្បូងឃ្មុំ កំពង់ចាម ក្រចេះ ស្ទួល÷

| ផលិតផល | កសិករដឹកទៅដល់ឃ្លាំង |
|---|---|
| ដំឡូងមីស្រស់ | ៣៨០៛-៤០០៛/គ.ក |
| ដំឡូងមីក្រៀម | ៧៥០៛-៨០០៛/គ.ក |

ជាទូទៅតម្លៃដំឡូងមីស្រស់របស់កម្ពុជាទាបជាងប្រទេសថៃ ដោយសារផលិតផលដំឡូងមីកម្ពុជាមានគុណភាពទាបជាងប្រទេសថៃ ព្រោះកសិករកម្ពុជាបង្ខំប្រមូលផលដំឡូងមីដោយមិនទាន់គ្រប់អាយុត្រឹមត្រូវ ដែលធ្វើឱ្យដំឡូងពុំមានម្សៅពេញលេញ ដោយសារដំឡូងនៅដើមរដូវមានតម្លៃខ្ពស់បន្តិចជាងពាក់កណ្តាលរដូវ មួយវិញទៀតកសិករត្រូវការប្រាក់ដើម្បីបង្វិលសងធនាគារ។

**៦-ទិន្នផល÷** តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ទិន្នផលដំឡូងមីជាមធ្យមគឺ២០.៧០តោន/ហ.ត ដំឡូងមីស្រស់ ប៉ុន្តែជាក់ស្តែងនៅតំបន់ខ្លះដូចជានៅម៉ាឡៃ កំរៀង ភ្នំព្រឹក ប៉ៃលិន កសិករអាចដាំបានរហូតដល់ចន្លោះពី៣០ ទៅ ៣៥តោន/ហ.ត ទៅតាមស្ថានភាពដី ការប្រើប្រាស់ជី ការប្រើថ្នាំបំប៉ន និងប្រភេទពូជ។ នៅតំបន់ខេត្តត្បូងឃ្មុំ កំពង់ចាម ទិន្នផលពី ២៥ ទៅ ៣០តោន/ហ.ត។

## ៧-ប្រតិទិនរដូវកាលនៃការដាំដុះ និងប្រមូលផល

| រដូវ | រដូវកាលដាំដុះ | រយៈពេលទទួលផល | រដូវប្រមូលផល |
|---|---|---|---|
| រដូវប្រាំង | ចាប់ផ្តើមដាំនៅក្នុងខែ កុម្ភៈ-មីនា | ប្រមូលផលក្រោយដាំបានពី ៩ ទៅ ១២ខែ | ចាប់ផ្តើមប្រមូលផលនៅខែ វិច្ឆិកា ដល់ ខែមីនា |
| រដូវវស្សា | ចាប់ផ្តើមដាំនៅក្នុងខែ ឧសភា-មិថុនា | ប្រមូលផលក្រោយដាំបានពី ៩ ទៅ ១២ខែ | ចាប់ផ្តើមប្រមូលផលនៅខែ កុម្ភៈ ដល់ ខែមេសា |

| ល.រ | សកម្មភាព | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ការត្រៀមពូជសម្រាប់ដាំដុះ | | | | | | | | | | | | |
| ២ | ការរៀបចំដី | | | | | | | | | | | | |
| ៣ | ការដាំដុះ | | | | | | | | | | | | |
| ៤ | បាញ់ថ្នាំ និងថែទាំ | | | | | | | | | | | | |
| ៥ | ប្រមូលផល | | | | | | | | | | | | |

ប្រភព: អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ៨-ថ្លៃដើមសម្រាប់ការដាំដុះ និងការថែទាំ ឆ្នាំ២០២០-២០២១

### ក/-ការចំណាយ និងលទ្ធផលក្នុងការដាំដំឡូងមី១ហិកតានៅតំបន់ស្រុកម៉ាឡៃ កំរៀង ភ្នំព្រឹក ប៉ៃលិន

### ក.១/-ការលក់ជាដំឡូងមីចំណិតក្រៀម

| ប្រភេទចំណាយ | ឯកតា | ចំនួន ឯកតា | តម្លៃ/ ឯកតា (បាត) | សរុប (ជាបាត) ក្នុងផ្ទៃដី១រ៉ៃ (បាត) | សរុប (ជាបាត) ក្នុងផ្ទៃដី១ហិកតា (១ហ.ត=៦.២៥រ៉ៃ) | សរុប (ជារៀល) ក្នុងផ្ទៃដី១ហិកតា ១បាត=១៣៣៖ |
|---|---|---|---|---|---|---|
| ថ្លៃភ្ជួររាស់ (ផាល៣ឬផាល៤) | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ថ្លៃសាប់ដី (ផាល៧) | លើក | 1.00 | 200.00 | 200.00 | 1,250.00 | |
| ថ្លៃពូនរង | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ជី ២០x២០x១៥ដាក់ពេលពូនរង | គ.ក | 17.00 | 18.00 | 306.00 | 1,912.50 | |
| ថ្លៃដាំ | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ពូជ | បាច់ | 40.00 | 25.00 | 1,000.00 | 6,250.00 | |
| ថ្លៃថែទាំបោចស្មៅ (បោចតែ១ថ្ងៃ=៤នាក់ ពេលដំឡូងអាយុ១ខែកន្លះទៅ២ខែ | នាក់ | 4.00 | 200.00 | 800.00 | 5,000.00 | |
| ថ្នាំបាញ់ស្មៅ (អាយុ២ខែកន្លះទៅ៣ខែ) | លើក | 1.00 | 45.00 | 45.00 | 281.25 | |
| ថ្លៃបាញ់ស្មៅ | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ថ្នាំប៉ូវ (ពេលដំឡូងអាយុ៣ខែ) | មីលីលីត្រ | 50.00 | 1.00 | 50.00 | 312.50 | |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី១(១ថ្ងៃ) | នាក់ | 2.00 | 300.00 | 600.00 | 3,750.00 | |
| ថ្នាំប៉ូវ (ដំឡូងអាយុ៤ខែកន្លះ) | មីលីលីត្រ | 50.00 | 1.00 | 50.00 | 312.50 | |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី២(១ថ្ងៃ) | នាក់ | 2.00 | 300.00 | 600.00 | 3,750.00 | |
| ថ្លៃកាប់ដើម (១បាច់=២៥ដើម) | បាច់ | 180.00 | 1.61 | 289.80 | 1,811.25 | |
| ខ្សែចងដើមដំឡូង | ដុំ | 1.00 | 24.20 | 24.20 | 151.25 | |
| ថ្លៃភ្ជួរគាស់មើម | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ឈ្នួលចិញ្ច្រាំ និងហាល តម្លៃ៨បាត/កញ្ចេ ដំឡូងស្រស់ ក្នុង១កញ្ចេទម្ងន់ ២៥គ.ក ទិន្នផល ៤៨០០គ.ក/រ៉ៃ=១៩២កញ្ចេ | កញ្ចេ | 192.00 | 8.00 | 1,536.00 | 9,600.00 | |
| ថ្លៃកម្មករប្រមូលដំឡូងស្ងួតច្រកការុង តម្លៃ៩.១បាត/ការុង ទម្ងន់៧៥គ.ក/ការុង (ដំឡូងស្រស់១០០០គ.ក បានដំឡូងស្ងួត ពី៥៥%ទៅ៦០%=៥៥០ ទៅ៦០០គ.ក) ទិន្នផល ៤៨០០គ.ក ដំឡូងមីស្រស់/រ៉ៃ ស្មើនឹង ២៦៤០គ.ក ដំឡូងស្ងួត (៥៥%) | ការុង | 35.00 | 9.10 | 318.50 | 1,990.63 | |

| | | | | | | |
|---|---|---|---|---|---|---|
| ស្មើនឹង៣៥ ការុងដំឡូងស្ងួត | | | | | | |
| ថ្លៃការុង | ការុង | 35.00 | 6.00 | 210.00 | 1,312.50 | |
| ថ្លៃកម្មករលើកដាក់ឡាន<br>១តោន=១០០បាត | គ.ក | 2,640.00 | 0.10 | 264.00 | 1,650.00 | |
| ថ្លៃដឹកទៅដល់សែឡ<br>១តោន=២០០បាត | គ.ក | 2,640.00 | 0.20 | 528.00 | 3,300.00 | |
| **សរុបចំណាយ** | | | | **8,321.50** | **52,009.38** | **6,917,246.88** |
| **ចំណូលសរុប** | | | | | | |
| លក់ដំឡូងមីចំណិតក្រៀម<br>តម្លៃដើមឆ្នាំ២០២១ ៥.៨បាត/គ.ក | គ.ក | 2,640.00 | 5.80 | **15,312.00** | **95,700.00** | **12,728,100.00** |
| **លទ្ធផល** | | | | **6,990.50** | **43,690.63** | **5,810,853.13** |

## ក.២/-ការលក់ជាមើមដំឡូងមីស្រស់

| ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា បាត | សរុប (ជាបាត) | | សរុប (ជារៀល) |
|---|---|---|---|---|---|---|
| | | | | ក្នុងផ្ទៃដី១រ៉ៃ | ក្នុងផ្ទៃដី១ហិកតា (១ហ.ត=៦.២៥រ៉ៃ) | ក្នុងផ្ទៃដី១ហិកតា ១បាត=១៣៣៖ |
| ថ្លៃភ្ជួររាស់ (ផាល៣ឬផាល៤) | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ថ្លៃសាប់ដី (ផាល៧) | លើក | 1.00 | 200.00 | 200.00 | 1,250.00 | |
| ថ្លៃពូនរង | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ជី ២០ x ២០ x ១៥ដាក់ពេលពូនរង | គ.ក | 17.00 | 18.00 | 306.00 | 1,912.50 | |
| ថ្លៃដាំ | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ពូជ | បាច់ | 40.00 | 25.00 | 1,000.00 | 6,250.00 | |
| ថ្លៃថែទាំបោចស្មៅ (បោចតែ១ថ្ងៃ=៤នាក់)<br>ពេលដំឡូងអាយុ១ខែកន្លះទៅ២ខែ | នាក់ | 4.00 | 200.00 | 800.00 | 5,000.00 | |
| ថ្នាំបាញ់ស្មៅ (អាយុ២ខែកន្លះទៅ៣ខែ) | លើក | 1.00 | 45.00 | 45.00 | 281.25 | |
| ថ្លៃបាញ់ស្មៅ | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ថ្នាំប៉ូវ (ពេលដំឡូងអាយុ៣ខែ) | មីលីលីត្រ | 50.00 | 1.00 | 50.00 | 312.50 | |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី១(១ថ្ងៃ) | នាក់ | 2.00 | 300.00 | 600.00 | 3,750.00 | |
| ថ្នាំប៉ូវ (ដំឡូងអាយុ៤ខែកន្លះ) | មីលីលីត្រ | 50.00 | 1.00 | 50.00 | 312.50 | |
| ថ្លៃបាញ់ថ្នាំប៉ូវលើកទី២(១ថ្ងៃ) | នាក់ | 2.00 | 300.00 | 600.00 | 3,750.00 | |
| ថ្លៃកាប់ដើម (១បាច់=២៥ដើម) | បាច់ | 180.00 | 1.61 | 289.80 | 1,811.25 | |
| ខ្សែចងដើមដំឡូង | ដុំ | 1.00 | 24.20 | 24.20 | 151.25 | |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្លៃភ្ជួរគាស់មើម | លើក | 1.00 | 300.00 | 300.00 | 1,875.00 | |
| ឈ្នួលកម្មករប្រមូលដំឡូង និងលើកដាក់ឡាន ១តោន= ៣០០បាត (ទិន្នផល ៤៨០០គ.ក/រ៉ៃ) | គ.ក | 4,800.00 | 0.30 | 1,440.00 | 9,000.00 | |
| ថ្លៃដឹកទៅដល់សៃឡូ (១តោន= ២០០បាត) | គ.ក | 4,800.00 | 0.20 | 960.00 | 6,000.00 | |
| **សរុបចំណាយ** | | | | **7,865.00** | **49,156.25** | **6,537,781.25** |
| **ចំណូលសរុប** | | | | | | |
| លក់ដំឡូងមីស្រស់ (ទិន្នផល ៤៨០០គ.ក/រ៉ៃ) តម្លៃដើមឆ្នាំ២០២១ ពី ២.៨បាត | គ.ក | 4,800.00 | 2.80 | **13,440.00** | **84,000.00** | **11,172,000.00** |
| **លទ្ធផល** | | | | **5,575.00** | **34,843.75** | **4,634,218.75** |

ប្រភព÷ លោក ចាន់ វិន ប្រធានសហគមន៍កសិកម្មឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ ០៩៧ ៣៧ ៤៧ ៣០៥

## ខ/-ការចំណាយ និងចំណូលក្នុងការដាំដំឡូងមី១ហិកតានៅខេត្តកំពង់ចាម ត្បូងឃ្មុំ លក់ជាដំឡូងមីស្រស់

### ខ.១/-<u>ចំពោះកសិករដែលអាចលក់ពូជឱ្យកសិករ</u> (កសិករចំនួន៦០% អាចលក់ពូជដើមដំឡូង)

| ល.រ | ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) |
|---|---|---|---|---|---|
| ១ | ថ្លៃរៀបចំដី ភ្ជួរ | លើក | 3 | 150,000 | 450,000 |
| ២ | ពូជ (ទាំងដាំ និងជួស) | បាច់ | 400 | 5,000 | 2,000,000 |
| ៣ | ដី (ដីក្បាលក្របី) ១បេ= ៥០គ.ក | បេ | 5 | 110,000 | 550,000 |
| ៤ | កម្លាំងពលកម្មដាំដុះ | នាក់ | 25 | 30,000 | 750,000 |
| ៥ | កម្លាំងពលកម្មធ្វើស្មៅ | នាក់ | 20 | 30,000 | 600,000 |
| ៦ | ថ្នាំស្មៅ (៥លីត្រ/កាន) | កាន | 2 | 45,000 | 90,000 |
| ៧ | អ្នកបាញ់ស្មៅ | នាក់ | 4 | 40,000 | 160,000 |
| ៨ | កម្លាំងប្រមូលផល | នាក់ | 20 | 30,000 | 600,000 |
| ៩ | ថ្លៃដឹកជញ្ជូនពីចម្ការទៅឃ្លាំង | តោន | 25 | 20,000 | 500,000 |
| **ចំណាយសរុប** | | | | | **5,700,000** |
| **ចំណូលសរុប** | | | | | **11,500,000** |
| ១ | ចំណូលពីការលក់មើមដំឡូងស្រស់ | គ.ក | 25,000 | 380 | 9,500,000 |
| ២ | ចំណូលពីការលក់ពូជដំឡូង | បាច់ | 400 | 5,000 | 2,000,000 |
| **ចំណេញសរុប** | | | | | **5,800,000** |

**ខ.២/-ចំពោះកសិករដែលត្រូវទិញពូជ ព្រោះមិនអាចទុកពូជដោយខ្លួនឯងបាន ដោយសារប្រភេទដីខ្លះធ្វើឱ្យដើមដំឡូងស្គម ក្រហមដើម និងមានផ្ទុកសត្វល្អិតឬជំងឺ (កសិករចំនួន៤០%ទិញពូជពីគេ)**

| ល.រ | ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប (រៀល) |
|---|---|---|---|---|---|
| ១ | ថ្លៃរៀបចំដី ភ្ជួរ | លើក | 3 | 150,000 | 450,000 |
| ២ | ពូជ (ទាំងដាំ និងជួស) | បាច់ | 400 | 5,000 | 2,000,000 |
| ៣ | ជី (ជីក្បាលក្របី) ១បេ=៥០គ.ក | បេ | 5 | 110,000 | 550,000 |
| ៤ | កម្លាំងពលកម្មដាំដុះ | នាក់ | 25 | 30,000 | 750,000 |
| ៥ | កម្លាំងពលកម្មធ្វើស្មៅ | នាក់ | 20 | 30,000 | 600,000 |
| ៦ | ថ្នាំស្មៅ (៥លីត្រ/កាន) | កាន | 2 | 45,000 | 90,000 |
| ៧ | អ្នកបាញ់ស្មៅ | នាក់ | 4 | 40,000 | 160,000 |
| ៨ | កម្លាំងប្រមូលផល | នាក់ | 20 | 30,000 | 600,000 |
| ៩ | ថ្លៃដឹកជញ្ជូនពីចម្ការទៅឃ្លាំង | តោន | 25 | 20,000 | 500,000 |
| **ចំណាយសរុប** | | | | | **5,700,000** |
| **ចំណូលសរុប** | | | | | **9,500,000** |
| ១ | ចំណូលពីការលក់មើមដំឡូងស្រស់ | គ.ក | 25,000 | 380 | 9,500,000 |
| **ចំណេញសរុប** | | | | | **3,800,000** |

ប្រភព÷ -លោក សេង សម្បត្តិ ប្រធានសហគមន៍ក្តីសង្ឃឹមកសិករ ស្រុកក្រូចឆ្មា ទូរស័ព្ទ ០៩៧ ៨៥០ ៨២៩២

-លោក សុន ភារ៉ា ប្រធានសហគមន៍តំបែររុងរឿង ស្រុកតំបែរ ទូរស័ព្ទ ០៩០ ៣២៨ ៧៨៧

## ៩-បច្ចេកទេសនៃការដាំដុះ និងថែទាំ

**ក.ការធ្វើដី÷** ដំឡូងមីត្រូវការដីផុះហើយជ្រៅ និងមិនជាំទឹក។ ត្រូវភ្ជួរដី ២លើក មុនចាប់ផ្តើមដាំ លើកទី១ ត្រូវភ្ជួរដីឱ្យបានជម្រៅពី ២ ទៅ ៣តឹក ដោយប្រើនង្គ័លផាល៣ រួចហាលដីចោលរយៈពេលពី ៧ទៅ១០ ថ្ងៃ ដើម្បីឱ្យងាប់ស្មៅ និងខ្សោះទឹកខ្លះ។ ភ្ជួរលើកទី២ គួរប្រើនង្គ័លផាល៧ ដើម្បីបំបែកដីឱ្យម៉ត់ និងស្មើល្អ ត្រីហាលដីចោលឱ្យខ្សោះទឹកល្មម មុនលើករង។

**ខ.ការលើករង÷** ចំពោះដីដែលច្រោះទឹកល្អ (ដីខ្សាច់ ដីក្រហម ឬដីមានចំណោត) មិនបាច់ពូនរងក៏បាន។ តែដីដែលជាំទឹកចាំបាច់ត្រូវពូនរង ដោយគម្លាត ១ ម៉ែត្រពីរងមួយទៅមួយ មានទទឹងពី ០,៥ ទៅ ០,៨ ម៉ែត្រ និងកម្ពស់ ០,៤ទៅ០,៥ម៉ែត្រ។

**គ. ការរៀបចំពូជ÷** រើសយកដើមណាដែលល្អមានអាយុពី ៨ខែ ឡើងទៅ ដើមថ្លោស គ្មានផ្ទុកសត្វល្អិត និងជំងឺ យកមកកាត់ជាកង់ៗដោយកាត់យកតែផ្នែកកណ្តាលប្រវែងពី២តឹកទៅ២តឹកកន្លះ ដែលមានភ្នែកពី ៥-៧ភ្នែកក្នុង១កំណាត់។ ត្រូវប្រើកាំបិតមុតឬរណាក្នុងការកាត់ដើមដំឡូងដើម្បីកុំឱ្យខ្ទាំសំបកឬបែកដើម។ យកល្អត្រូវចុចមុខកាត់ទាំងសងខាងចូលក្នុងផេះចំបើងដើម្បីទប់ស្កាត់កុំឱ្យវាហូរជ័រចេញច្រើនពេក។

**ឃ. ការប្រើពូជ÷** នៅតំបន់ខេត្តកំពង់ចាម ត្បូងឃ្មុំ កសិករប្រើពូជ រ:យ៉ង៧២ ឬ រ:យ៉ង៩ (ថៃ) ពូជមីយ៉ុង (វៀតណាម) ឬពូជ KU50។ នៅតំបន់ខេត្តបាត់ដំបង និងបន្ទាយមានជ័យ កសិករប្រើពូជ រ:យ៉ង៧២ រ:យ៉ង៩ ប៉ុន្តែភាគច្រើនប្រើពូជ ហ៊ុយ ប៊ុង ដែលផ្តល់កម្រិតជាតិម្សៅខ្ពស់។

**ង. រដូវដាំដុះ÷** ជ្រើសរើសយកពេលដែលដីមានសំណើមគ្រប់គ្រាន់ គឺគេច្រើនដាំនៅខែកុម្ភៈ និង មីនា ពោលគឺបន្ទាប់ពីមានភ្លៀងកក់ខែធ្លាក់។

**ច. វិធីដាំ÷**

-តាមការអនុវត្តជាក់ស្តែងរបស់កសិករ គឺយកកំណាត់ដើមដំឡូងផ្តេកហើយកប់រាក់ៗក្នុងរងក៏បាន ឬដោតបញ្ឈរពីលើរងក៏បាន។ ទាំង២វិធីនេះ ត្រូវទុកចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែងប្រមាណ៨តឹក រីឯចន្លោះជួរគឺត្រូវទុក ១ម៉ែត្រ។ ដាំកណ្តាលរង ១ជួរក្នុង១រង

-តាមលក្ខណៈបច្ចេកទេសដែលរៀបចំដោយកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ការរៀបចំដី និងការដាំដុះគឺអនុវត្តដូចខាងក្រោម÷

- ការលើករង÷ លើករង ១ម៉ែត្រ កម្ពស់២០-៣០សង់ទីម៉ែត្រ
- វិធីដាំ÷ ដាំបញ្ឈរ ដាំបញ្ឆិត ដាំផ្តេក
- ចន្លោះជួរ និងគុម្ព

| ចន្លោះពី១ជួរទៅ១ជួរ | ចន្លោះពី១ដើមទៅ១ដើម | ចំនួនដើម |
|---|---|---|
| ៩០ ស.ម | ៦០ ស.ម | ១៨.០០០ដើម/ហ.ត |
| ៩០ ស.ម | ៩០ ស.ម | ១២.០០០ដើម/ហ.ត |

**ឆ. ការប្រើប្រាស់ជី÷**

**ឆ.១.** តាមការអនុវត្តជាក់ស្តែងរបស់កសិករនៅម៉ាឡៃ កំរៀង សំពៅលូន÷

- ជី ២០x២០x១៥ ដាក់ពេលពូនរងចំនួន ១០៦គ.ក/ហ.ត
- ថ្នាំប៉ូវ (ពេលដំឡូងអាយុ៣ខែ) ចំនួន ៣១៣ មីលីលីត្រ/ហ.ត
- ថ្នាំប៉ូវ (ពេលដំឡូងអាយុ៤ខែកន្លះ) ចំនួន ៣១៣មីលីលីត្រ/ហ.ត

**ឆ.២.** តាមការអនុវត្តជាក់ស្តែងរបស់កសិករនៅស្រុកតំបែរ ក្រូចឆ្មារ ត្បូងឃ្មុំ÷

- ជីទ្រាប់បាតដោយប្រើជីធម្មជាតិឬជី DAP ចំនួន១០០គ.ក/ហ.ត
- ជីបំប៉នលើកទី១ ពេលដំឡូងអាយុបាន១ខែកន្លះ ប្រើជីក្បាលក្របីឬអ៊ុយរ៉េចំនួន ១០០គ.ក/ហ.ត
- ជីបំប៉នលើកទី២ ពេលដំឡូងអាយុបាន៥ខែ ប្រើជីក្បាលក្របីចំនួន ៥០គ.ក/ហ.ត

**ឆ.៣.** តាមបច្ចេកទេសរបស់ (ASPIRE) ÷

- ជីទ្រាប់បាត÷ ប្រភេទ DAP ១០០គ.ក អ៊ុយរ៉េ ៧៥គ.ក និងជីកាលី ៧៥គ.ក/ហ.ត
- ជីបំប៉ន÷ជីអ៊ុយរ៉េ៧៥គ.ក និងជីកាលី៧៥គ.ក/ហ.ត ក្រោយដាំ៤៥ថ្ងៃដល់២ខែ

**ឆ.៤.** តាមបច្ចេកទេសរបស់កសិករនៅខេត្តឧត្តរមានជ័យ÷

- ជីទ្រាប់បាត÷ ប្រភេទ DAP ១០០គ.ក អ៊ុយរ៉េ ៥០គ.ក និងជីកាលី ៥០គ.ក/ហ.ត
- ជីបំប៉ន (ដាក់តែម្តងគត់) ÷ អ៊ុយរ៉េ ១០០គ.ក និងជីកាលី ១០០គ.ក/ហ.ត

ការប្រើប្រាស់ជីបំប៉នគឺដាក់ចន្លោះគុម្ពដោយកាយដីដាក់ ហើយលុបវិញ។

**ជ. ការថែទាំ÷** -ចាប់ផ្តើមធ្វើស្មៅ (បោចដោយដៃ) ពេលដំឡូងអាយុបាន១ខែកន្លះទៅ២ខែ

-បាញ់ថ្នាំស្មៅពេលដំឡូងអាយុបាន២ខែកន្លះទៅ៣ខែ

(ហាមបាញ់ថ្នាំសម្លាប់ស្មៅនៅពេលដំឡូងកំពុងលូតលាស់ខ្ចីនៅឡើយ ដែលធ្វើឱ្យអាក់ខានដល់ការលូតលាស់របស់ដំណាំ)

**១០-<u>ការប្រមូលផល</u>÷**

ជាទូទៅការប្រមូលផលធ្វើឡើងក្រោយដាំបានពី៩ ទៅ១២ខែ គឺដាំនៅចុងខែ២ដល់ដើមខែ៣ និងប្រមូលផលនៅចុងខែ១២ដល់ខែ៣ លក្ខណៈសម្គាល់គឺស្លឹកវាឡើងពណ៌លឿងហើយចាប់ផ្តើមជ្រុះស្លឹកនៅគល់ដេញឡើងទៅលើ។ មុនគាស់មើមត្រូវកាប់ដើមចេញសិនដោយទុកប្រហែល ៣០-៤០ ស.ម ពីដី។ ការប្រមូលផលប្រែប្រួលទៅតាមប្រភេទពូជ និងសេចក្តីត្រូវការរបស់អ្នកដាំ។ តាមការអនុវត្តនិងបទ-ពិសោធន៍ជាក់ស្តែងរបស់កសិករ ប្រសិនបើការប្រមូលផលអនុវត្តក្រោយដាំបានពី៩ទៅ១០ខែ នោះទិន្នផលទទួលបានគឺតិចជាងការប្រមូលផលក្រោយដាំបានពី១១ទៅ១២ខែ។ ប៉ុន្តែកសិករមួយចំនួនដែលជាប់បំណុលនៅធនាគារគឺស្រូតប្រមូលផលដើម្បីលក់យកប្រាក់សងធនាគារវិញ។

**<u>ក-ការប្រមូលផលអនុវត្តក្រោយដាំបានពី៩ទៅ១០ខែ÷</u>**

-ទិន្នផល ២០-២៥តោន/ហ.ត ដំឡូងមីស្រស់

-ក្នុងបរិមាណដំឡូងមីស្រស់ ១០០០គ.ក ទទួលបានដំឡូងមីចំណិតក្រៀមចំនួន ៤២០ គ.ក ដោយសារកម្រិតជាតិម្សៅក្នុងដំឡូងមិនទាន់ពេញល្អ

ខ-ការប្រមូលផលអនុវត្តក្រោយដាំបាន ១២ខែ÷

-ទិន្នផល ២៥-៣៥តោន/ហ.ត ដំឡូងមីស្រស់

-ក្នុងបរិមាណដំឡូងមីស្រស់ ១០០០គ.ក ទទួលបានដំឡូងមីចំណិតក្រៀមចំនួន ៥៥០គ.ក ទៅ ៦០០ គ.ក ដោយសារជាតិម្សៅក្នុងដំឡូងណែនល្អ (ដំឡូងប្រភេទនេះពិបាកក្នុងការចិញ្ច្រាំព្រោះវារឹង) មិនត្រូវពន្យាពេលក្នុងការប្រមូលផលដំឡូងមីយូរពេកនោះទេ ព្រោះអាចធ្វើឱ្យកម្រិតម្សៅរបស់មើមថយចុះ កើនសរសៃ និងធ្វើឱ្យរឹង។

## ១១-ចំណុចខ្លាំង

-មិនដូចដំណាំដទៃ ដំឡូងមីកម្រងាប់ណាស់ព្រោះធន់នឹងភាពរាំងស្ងួត ទោះស្លឹកឈប់ដុះនិងស្លឹកចាស់អាចជ្រុះចេញប៉ុន្តែវានឹងដុះវិញពេលមានភ្លៀង។ ដំណាំដំឡូងមីដុះបានល្អបំផុតពេលមានសំណើមដី តែមិនធន់នឹងការជាំទឹកទេ

-កសិករតែងផ្តល់បទពិសោធន៍ពីភាពជោគជ័យនៃការដាំឱ្យគ្នាទៅវិញទៅមក ដែលធ្វើឱ្យកសិករមានការយល់ដឹងកាន់តែច្បាស់ពីវិធីនៃការដាំដុះពី១ឆ្នាំទៅ១ឆ្នាំ ដែលអាចទទួលបានចំណូលសមរម្យ

-គ្រួសារនៅជនបទទទួលបានប្រាក់ចំណូលនិងកម្រៃពីការដាំដុះ និងស៊ីឈ្នួលពលកម្មសម្រាប់ការកែច្នៃពីដំឡូងមីស្រស់ទៅជាដំឡូងមីចំណិតក្រៀម។

## ១២-បញ្ហាប្រឈម

-បច្ចេកទេសដាំដុះ កសិករដាំដំឡូងមីសព្វថ្ងៃភាគច្រើនគឺតាមទម្លាប់ប្រពៃណីទាំងស្រុង ប្រាប់តៗគ្នា ដែលប្រការនេះធ្វើឱ្យដំឡូងមីខ្មែរលក់បានថោក ដោយមិនត្រូវតាមស្តង់ដារទីផ្សារអន្តរជាតិ

-កសិករដាំដុះតាមរបៀបផ្សងព្រេង ឆ្នាំខ្លះបានផល ឆ្នាំខ្លះក៏មិនបានផល

-ដំឡូងមី ជាដំណាំដែលងាយទទួលរងការបំផ្លាញពីពួកសត្វល្អិតចង្រៃ និងជំងឺផ្សេងៗច្រើនប្រភេទដែលបង្កឡើងពីពពួកវីរុស អាចបំផ្លាញដល់ដំឡូងមី ដូចជាជំងឺអុចត្នោតកើតលើស្លឹក ជំងឺរលួយដើម ជំងឺរលួយឫស និងប្រភេទសត្វល្អិតចង្រៃ ដូចជាពពួកចៃជាដើម។

-ជួបប្រទះនូវគ្រោះរាំងស្ងួតរយៈពេលវែងដែលធ្វើឱ្យអត្រានៃការរស់រានរបស់ដំឡូងមីទាប និង បង្កើនថ្លៃដាំដុះ (ជួស និងបង្កើនជី) ពេលខ្លះភ្លៀងជោគជាំខ្លាំងធ្វើឱ្យដំឡូងរលួយឬស